# រឿង ដើមកោងកាង និង
# ដើមឈើទាល



# ដើមកោងកាង និងដើមឈើទាល

រៀបរៀងដោយអ្នកស្រី ឱម ធិរិទ្ធ

គូររូបដោយលោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្នេហ៍គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០១១

សៀវភៅរូបភាពសម្រាប់កុមារ លេខ ១០៨

# រឿង ដើមកោចកាច និងដើមឈើទាល

ដកស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគ ៧

បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

រៀបរៀងដោយ ឱម ជីវិទ្ធ

គូររូបភាពដោយ ចាន់ សោភ័ណ

ត្រួតពិនិត្យដោយ វ៉ា សំអាត ព្រំ វិចិត្រ ឆាយ ផល្លី

សៀវភៅនេះ បានទទួលការអនុញ្ញាតឱ្យបោះពុម្ពពីក្រសួងអប់រំយុវជន និងកីឡា តាមប្រកាសលេខ ២៥៤៥ អយក.ប្រក ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីប្រើប្រាស់ជាប្រភេទសៀវភៅអានបន្ថែមនៅតាមសាលារៀនចំណេះទូទៅ ។



បោះពុម្ពលើកទី ១ ចំនួន ៣ ០០០ ច្បាប់

ISBN: 978-99950-56-41-4

©រក្សាសិទ្ធិដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពនៅរោងពុម្ព SOK HENG Printing House

ភ្នំពេញ ខែ វិច្ឆិកា ឆ្នាំ ២០១១

មានរឿងតំណាលតៗគ្នាពីបុរាណមកថា កាលដើមឡើយ ដើមកោងកាងជាឈើមួយពួកដែលដុះនៅតែលើភ្នំ និងជើងភ្នំ ។



ចំណែក ដើមឈើទាលផុះនៅតែក្បែរមាត់ព្រែក មាត់ស្ទឹង និង មាត់អូរ ។ នៅរដូវទឹកជំនន់ ភ្លៀងតែងតែហូរច្រោះ ធ្វើឱ្យរលើងរលំ ដើមឈើទាលស្លាប់អន្តរាយអស់ ។





ដើមឈើទាលទាំងឡាយ កាលបើបានជួបក្តីវេទនា ក៏ជំនុំគ្នាថា "យើងនឹងទ្រាំដុះលើដីទំនាបយ៉ាងនេះតទៅទៀតពុំបានឡើយ ។ យើងត្រូវនាំគ្នាទៅនិយាយជាមួយនឹងដើមកោងកាង ឱ្យមកដុះនៅលើដីមានសភាពជ្រុះវិញ ព្រោះពួកគេមានឫសច្រើន" ។





លុះជំនុំព្រមព្រៀងគ្នាហើយ ពួកដើមឈើទាលទាំងអស់បានចូលទៅនិយាយជាមួយនឹងដើមកោងកាងឱ្យផ្លាស់ប្តូរទីកន្លែងមកដុះដីទំនាបក្បែរមាត់ទឹកវិញម្តង ។



ដំបូង ដើមកោងកាងប្រកែកយ៉ាងខ្លាំង តែដោយដើមឈើទាលអង្វរហើយ អង្វរទៀតថា "បើអ្នកព្រមជូរមកជុះនៅកន្លែងពួកយើង ពួកយើងរាល់គ្នានឹងតបឧបការគុណអ្នករាល់ឆ្នាំជាដរាបទៅ គឺក្នុងមួយឆ្នាំយើងនឹងកោរសក់បួសជូនម្តង" ។







ឯដើមកោងកាង កាលបើឮដើមឈើទាលអង្វរយ៉ាងដូច្នោះហើយ ក៏ព្រមចុះមកដុះនៅក្បែរមាត់ទឹកតាមដើមឈើទាលសុំរហូតមក ។ ឯដើមឈើទាលក៏នាំគ្នាឡើងទៅដុះលើភ្នំ និងជើងភ្នំវិញ ។



ព្រោះហេតុនេះហើយ  បានជាសព្វថ្ងៃនេះ នៅលើភ្នំ និង
តាមជើងភ្នំ គេច្រើនឃើញមានតែដើមឈើទាលដុះពាសពេញ ។



ចំណែកឯដើមកោងកាង គេឃើញដុះនៅតាមមាត់ព្រែក មាត់ស្ទឹង មាត់អូរ និងមាត់សមុទ្រជាដរាបមក ។



ម្យ៉ាងទៀតសព្វថ្ងៃនេះ គេតែងសង្កេតឃើញដើមឈើទាលជម្រុះស្លឹកអស់រលីងក្នុងមួយឆ្នាំម្តង គឺបួសជូនដើមកោងកាង ។







ចំណែកដើមកោងកាង កាលបើបានទៅផុះនៅក្បែរមាត់ទឹក កាលណាតែងលបលួចចែចង់កូនក្រមុំដើមភ្លាំពូរៀងរាល់យប់ ។ ឯនាងភ្លាំពូខឹងខ្លាំងណាស់ បានយកឈើទៅបោះចម្រូងពាសពេញ ដើម្បីមិនឱ្យដើមកោងកាងលបលួចចែចង់កូនក្រមុំខ្លួន ។





ឯចំណែកដើមកោងកាង  កាលបើត្រូវដើមភ្លាំពួបោះចម្រូង មិនឱ្យចូលចុះបានក៏ប្រឹងបោះស្ពានឆ្លងកាត់ចម្រូងនោះទៅទៀត ។ ហេតុនេះហើយ  បានជាសព្វថ្ងៃនេះ  នៅទីកន្លែងណាមាន ដើមកោងកាងដុះ គេតែងឃើញមានដើមភ្លាំពួដុះនៅទីនោះជាដរាប ។



ចំណែកដើមត្លាំពូដែលដុះឡើងនោះ បើក្រឡេកមើលទៅឃើញ ហាក់ដូចជាចម្រូងពិតៗ ដោយសារដើមនោះមូល ហើយស្រួចៗដុះច្រូងច្រាងជាជួរដូចគេដាំ ។







ចំណែកឯដើមកោងកាងសោតទៀត ក៏មានឫសវែងៗធំៗ ចាក់ស្រេះទៅក្នុងដី ក្នុងទឹកជាច្រើន  គឺច្រើនជាងមែកទៅទៀត ហើយក៏ជាទីជម្រក  របស់សត្វទាំងពួងស្នាក់អាស្រ័យផងដែរ ។





អាស្រ័យដោយភាពរឹងមាំរបស់ឫសនេះហើយ ទោះបីជាទឹករលក ឬទឹកជំនន់ហូរច្រោះខ្លាំងយ៉ាងណាក៏ដោយ ក៏មិនអាចរំលើងរំលំដើមកោងកាងបានឡើយ ៕

……ចប់……



*Move forward, hand in hand.*
Shanti Volunteer Association
*Stand with people in need around the world*

9 789995 056414